01391441

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

D193/91/7

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៩)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម នេយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 02 / 2017
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ: កោសលុប**

**សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍រួមរបស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើការដាក់បញ្ចូលឯកសារ (D193/76 និង D193/77) និងសំណើសុំដាក់បញ្ចូលឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បញ្ចូលឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75)**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី [redacted]**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី

Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៨១៤ ទូរសារ (៨៥៥) ២៣ ២១៩ ៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh, Cambodia, PO Box 71, Tel: (855) 23 219 814 Fax: (855) 23 219 841 Web: www.eccc.gov.kh

សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៩)

ឯកសារលេខ D193/91/7

សូ មូស្សេទ្ធី
Susana TOMANOVIĆ

សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE

Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

*សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍រួមរបស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76 និង D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75 និង D193/84)*

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍រួមរបស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76 និង D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (សពរអ) សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75) ដែលសហមេធាវីការពារក្តីរបស់គាត់ ("មេធាវីការពារក្តី") បានដាក់ជាភាសាអង់គ្លេស នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ និងបានដាក់ជាភាសាខ្មែរ នៅថ្ងៃទី០៦ ខែ កញ្ញា ឆ្នាំ ២០១៦ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

1. បណ្តឹងឧទ្ធរណ៍នេះ ពាក់ព័ន្ធទៅនឹងដីកាសម្រេចចំនួនពីរគឺ ឯកសារ D193/89 ("ដីកាសម្រេចលើកទីមួយ ដែលត្រូវបានជំទាស់")[2] និងឯកសារ D193/90 ("ដីកាសម្រេចលើកទីពីរ ដែលត្រូវបានជំទាស់")[3] ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Bolhander ("សចសអ") បានចេញកាលពី

---

[1] បណ្តឹងឧទ្ធរណ៍រួមរបស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76 និង D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75 និង D193/84) ឯកសារ D193/91/2 ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦។

[2] ដីកាសម្រេចរួមលើសំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76 និង D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D193/89។

[3] ដីកាសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75) ចុះថ្ងៃ ១៥ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D193/90។ អបជ កត់សម្គាល់ឃើញថា *សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍រួមរបស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76 និង D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75 និង D193/84)*

ថ្ងៃទី ១៣ និងថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦ ដាច់ដោយឡែកពីគ្នា ទាក់ទងនឹងសំណើនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("សពអ") សុំដាក់បង្ហាញឯកសារ និងសំណើផ្សេងទៀតរបស់មេធាវីការពារក្តី [redacted] ដែលសុំឱ្យធ្វើការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចនានាលើសំណើសុំឱ្យដាក់បង្ហាញឯកសារ។

## II. ប្រវត្តិនីតិវិធី

### ១. កិច្ចដំណើរការនីតិវិធីនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត (កសចស)

2. នៅថ្ងៃទី ០៨ ខែ ឧសភា និងថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon ("អតីត សចសអ") បានចេញដីកាសម្រេចចំនួនពីរចំពោះសំណើមួយចំនួនរបស់ សពអ ដែលសុំឱ្យដាក់បង្ហាញឯកសារ ("ដីកាសម្រេចរបស់អតីត សចសអ")[4]។ នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ សពអ បានដាក់សេចក្តីថ្លែងការណ៍ជាសាធារណមួយ ដោយជូនដំណឹងថា សចសអ បានអនុញ្ញាតឱ្យយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ២៧ ពីសំណុំរឿង ០០៤ មកបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង និងជូនភាគីដទៃទៀតក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧ អ.វ.ត.ក/កសចស (សំណុំរឿង០០២)[5]។ នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្តី

---

នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ កសចស បានធ្វើការកែតម្រូវនៅត្រង់ទំព័រទី ១ នៃដីកាសម្រេចលើកទីពីរដែលត្រូវបានជំទាស់ ដែលបានលុបឯកសារ D193/84 ចេញពីចំណងជើងឯកសារ (សូមមើល ឯកសារ D193/90/ កែតម្រូវ ១)។

[4] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបង្ហាញកំណត់ហេតុស្តាប់ចម្លើយក្នុងសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ *និង* ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាសុំឱ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី ១ នៃការជំនុំជម្រះក្តី ទៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D193/4។ *សូមមើល ផងដែរ* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩ និងលេខយោងជើងទំព័រ ៤៤។

[5] ការដាក់បង្ហាញកំណត់ហេតុពីសំណុំរឿង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៤ ឯកសារ E319 ។

របស់ [redacted] បានដាក់សំណើមួយនៅចំពោះមុខ កសចស សុំសិទ្ធិចូលមើលឯកសារចំនួនប្រាំ ដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ សពអ[6]។ នៅថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អតីត សចសអ បានបដិសេធសំណើរបស់ [redacted] សុំសិទ្ធិចូលមើលឯកសារទាំងប្រាំ ដោយលើកសំអាងថា ក្នុងឋានៈជាជនសង្ស័យ គាត់មិនមាន "រឿងក្តីត្រូវឆ្លើយនៅដំណាក់កាលនេះឡើយ"[7]។

3. នៅថ្ងៃទី ១១ ខែ មីនា និងថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ អតីត សចសអ បានចេញដីកា D193/15 និង D193/24 សម្រេចលើសំណើរបស់ សពអ សុំដាក់បង្ហាញឯកសារ D193/7 D193/9 និងឯកសារ D193/23[8] ព្រមទាំង អនុញ្ញាតឱ្យដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ឯកសារ D119/84 និង D119/85 ក្នុងចំណោមឯកសារជាច្រើនទៀត[9]។

---

[6] សំណើជាបន្ទាន់របស់ [redacted] សុំឯកសារចំនួនប្រាំដែលបានយោងនៅក្នុង "ការដាក់បង្ហាញកំណត់ហេតុពីសំណុំរឿង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ" ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D226។

[7] ដីកាសម្រេចលើសំណើរបស់ជនសង្ស័យសុំឯកសារចំនួនប្រាំ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D226/1 កថាខណ្ឌ ១១។

[8] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង ០០២/០២ និងបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D193/7 ។ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង ០០២/០២ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D193/9។ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង ០០២ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D193/23។

[9] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារ D193, D193/7 និង D193/9 សម្រាប់សំណុំរឿង ០០២ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D193/15។ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារ D193, D193/7 និង D193/23 សម្រាប់សំណុំរឿង ០០២ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D193/24។

01391446



4. នៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ សចសអ បានចេញអនុស្សរណៈ*សម្ងាត់* មួយ គឺឯកសារ D273 ផ្ញើជូនទៅអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ដែលមានកម្មវត្ថុថា "ការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ទៅសំណុំរឿង ០០២" ("អនុស្សរណៈ D273 ស្តីពីការសុំដាក់បង្ហាញឯកសារ"[10] ដែលយោងទៅ "ការកែប្រែទម្លាប់នៃការអនុវត្តនីតិវិធីដាក់បង្ហាញឯកសារ"[11]។

5. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ [redacted] បានចូលខ្លួនមកចំពោះមុខ សចសអ ដែលបានជូនដំណឹងគាត់អំពីបទចោទនានា និងបានផ្តល់សិទ្ធិឱ្យមេធាវីការពារក្តីរបស់គាត់ចូលមើលសំណុំរឿង ០០៤/០៧-០៩-២០០៩ អ.វ.ត.ក/កសចស (សំណុំរឿង ០០៤)[12]។

6. នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ សចសអ បានចេញដីកាសម្រេច D193/69 ដោយបានយល់ព្រមទទួលយកសំណើរបស់ សពអ គឺឯកសារ D193/68 ដែលស្នើសុំដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] គឺឯកសារ D219/488 និងបានកែប្រែ ដោយយោងទៅអនុស្សរណៈ D273 ស្តីពីការសុំដាក់បង្ហាញឯកសារ លក្ខខណ្ឌមួយចំនួនសម្រាប់ការដាក់បង្ហាញកំណត់ហេតុផ្សេងទៀតនៃការស្តាប់ចម្លើយសាក្សី [redacted] គឺ ឯកសារ D119/85, D119/86 និង D119/87 ដែលត្រូវបានយកមកដាក់បង្ហាញកាលពីលើកមុនរួចហើយ តាមរយៈដីកាសម្រេច D193/24[13]។

---

[10] អនុស្សរណៈពី សចសអ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹង "ការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ទៅក្នុងសំណុំរឿង ០០២" ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D273។

[11] *ដូចខាងលើ* កថាខណ្ឌ ៣។

[12] [កែតម្រូវ ១] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ [redacted] ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D281។

[13] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារមួយពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D193/69។

7. នៅថ្ងៃទី ០៤ ថ្ងៃទី ១០ និងថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ សពអ បានដាក់សំណើ D193/70 សុំដាក់បង្ហាញឯកសារ[14] សំណើសុំដាក់បង្ហាញឯកសារ D193/72 ("សំណើ D193/72"[15]) និងសំណើ D193/75 ដាច់ដោយឡែកៗពីគ្នា[16]។ នៅក្នុងសំណើ D193/72 សពអ បានស្នើសុំដាក់បង្ហាញឯកសារចំនួនបួនច្បាប់ គឺ ឯកសារ D119/84.1, D119/85.1, D119/85.2 និង D119/87.1 ដែលភ្ជាប់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ដែលត្រូវបានបង្ហាញកាលពីមុនរួចហើយនោះ។

8. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើសុំឱ្យធ្វើការពិចារណាឡើងវិញចំពោះដីកាសម្រេច D193/69 ("សំណើសុំឱ្យធ្វើការពិចារណាឡើងវិញលើកទីមួយ")[17]។ នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើមួយទៀត សុំឱ្យពិចារណាឡើងវិញលើផ្នែកខ្លះនៃដីកាសម្រេច D193/15 និង D193/24 របស់ អតីត សចសអ និងចម្លើយតបទៅនឹងសំណើរបស់ សពអ D193/72 ("សំណើសុំឱ្យធ្វើការពិចារណាឡើងវិញលើកទីពីរ")[18]។

---

[14] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២ និងសុះដកហូតការកោសលុប ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D193/70។

[15] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារភ្ជាប់ទៅនឹងឯកសារ ដែលបានដាក់បង្ហាញទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D193/72។

[16] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D193/75។

[17] សំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញ ចំពោះដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារមួយពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/69) ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D193/76។

[18] សំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើផ្នែកខ្លះនៃឯកសារ D193/15 និង D193/24 និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ D193/72 ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D193/77។

9. នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦ សចសអ បានចេញដីកាសម្រេចលើកទីមួយដែលត្រូវបានជំទាស់ ដោយបានបដិសេធសំណើរបស់មេធាវីការពារក្ដីសុំឱ្យធ្វើការពិចារណាឡើងវិញលើកទីមួយ និងលើកទីពីរ ព្រមទាំងបានយល់ព្រមតាមផ្នែកខ្លះនៃសំណើ សពរអ ឯកសារ D193/72។ នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦ សចសអ បានចេញដីកាសម្រេចលើកទីពីរដែលត្រូវបានជំទាស់ ដែលយល់ព្រមតាមសំណើ D193/70 D193/72 និង D193/75 សុំដាក់បង្ហាញឯកសារ។

10. នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ មេធាវីការពារក្ដីបានដាក់ការជូនដំណឹងនៅចំពោះមុខ កសចស អំពីបណ្ដឹងឧទ្ធរណ៍រួមប្រឆាំងនឹងដីកាសម្រេចដែលត្រូវបានជំទាស់លើកទីមួយ និងលើកទីពីរ[19]។

## ២. កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ

11. នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ មេធាវីការពារក្ដីការពារក្ដីបានដាក់បណ្ដឹងឧទ្ធរណ៍រួម តែជាភាសាអង់គ្លេសសិន នៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយក្រោយមកបានដាក់សំណើមួយទៀតចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ សុំការអនុញ្ញាតដាក់បណ្ដឹងឧទ្ធរណ៍តែមួយភាសាសិន ហើយនឹងដាក់ជូនសំណៅបកប្រែតាមក្រោយ ("សំណើរបស់មេធាវីការពារក្ដីលើផ្នែកភាសា")[20]។ យោងតាមសំណើរបស់មេធាវីការពារក្ដីលើផ្នែកភាសានេះ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានទទួលការជូនដំណឹងអំពីដីកាសម្រេចលើកទីមួយដែលត្រូវបានជំទាស់ នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦[21] និងបានទទួលតាមរយៈអ៊ីម៉ែលដីកាសម្រេចលើកទីពីរដែលត្រូវបានជំទាស់ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ

---

[19] សៀវភៅចុះបណ្ដឹងឧទ្ធរណ៍នៃការជូនដំណឹងរបស់ [redacted] អំពីបណ្ដឹងឧទ្ធរណ៍រួមប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76 និង D193/77) និងប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75 និង D193/84) ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ D193/91។

[20] សំណើសុំការអនុញ្ញាតដើម្បីដាក់បណ្ដឹងឧទ្ធរណ៍រួមរបស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឯកសារ D193/89 និង D193/90 តែមួយភាសា ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ D193/91/1។

[21] *ដូចខាងលើ* កថាខណ្ឌ ១។

២០១៦ តែជាភាសាអង់គ្លេសតែប៉ុណ្ណោះ[22]។ សំណៅបកប្រែជាភាសាខ្មែរនៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានដាក់ជូននៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦។

12. នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦ ក្រោយពីបានពិចារណាថា (១) សំណើរបស់មេធាវីការពារក្តីលើផ្នែកភាសា បានផ្តល់មូលហេតុដែលទទួលយកបាន (២) សពអ មិនបានលើកឡើងនូវការជំទាស់ណាមួយឡើយ (៣) សំណៅជាភាសាអង់គ្លេសនៃបណ្តឹងឧទ្ធរណ៍រួមនេះ ត្រូវបានដាក់ជូននៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ និង (៤) នៅពេលដែលមេធាវីការពារក្តីដាក់បណ្តឹងឧទ្ធរណ៍រួមនេះជាភាសាអង់គ្លេស ម្ចាស់បណ្តឹងឧទ្ធរណ៍មិនទាន់បានទទួលសំណៅជាភាសាខ្មែរនៃដីកាសម្រេចដែលត្រូវបានជំទាស់លើកទីពីរនេះនៅឡើយទេ[23] អង្គបុរេជំនុំជម្រះបានយល់ព្រមតាមសំណើរបស់មេធាវីការពារក្តីលើផ្នែកភាសា និងបានអនុញ្ញាតឱ្យធ្វើការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍រួមនេះ។ ទោះបីជាវិធានផ្ទៃក្នុងមិនមានចែងអំពី ការអនុញ្ញាតឱ្យដាក់បណ្តឹងឧទ្ធរណ៍ *"រួម"* ប្រឆាំងនឹងដីកាសម្រេច "ច្រើន"[24] ក៏ដោយ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យដាក់បណ្តឹងឧទ្ធរណ៍ *រួម* ប្រឆាំងនឹងដីកាសម្រេចដែលត្រូវបានជំទាស់*ទាំងពីរលើកនេះ* ដោយហេតុថា មិនមានការជំទាស់ណាមួយត្រូវបានលើកឡើងពាក់ព័ន្ធនឹងបញ្ហានេះទេ ហើយ សំខាន់បំផុតនោះ ក្រោយពីបានយល់ឃើញថា ដីកាសម្រេចដែលត្រូវបានជំទាស់ទាំងពីរលើកនេះ (១) ទាក់ទិននឹងកម្មវត្ថុនៃការសុំដាក់បង្ហាញឯកសារស៊ើបអង្កេតនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះដូចគ្នា (២) សំអាងហេតុនៃដីកាសម្រេចទាំងពីរនេះ បានណែនាំឱ្យអានផ្ទួបគ្នាជាមួយនឹងដីកាសម្រេចដទៃទៀតរបស់ សចសអ

---

[22] *ដូចខាងលើ* កថាខណ្ឌ ២។

[23] សំណើរបស់មេធាវីការពារក្តីលើផ្នែកភាសា កថាខណ្ឌ ២។ *សូមមើល ផងដែរ* សំនុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ២៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹងការផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះនៅក្នុងសវនាការអសាធារណៈ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D309/6 កថាខណ្ឌ ១៤៖ "ដោយសារតែសំណៅបកប្រែជាភាសាខ្មែរនៃដីកាដែលរងការជំទាស់ មិនទាន់ត្រូវបានជូនដំណឹងនៅឡើយ នោះការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ និងបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់នៅក្នុងពេលវេលាកំណត់ ដោយអនុលោមតាមវិធានផ្ទៃក្នុង"។

[24] អ.វ.ត.ក វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) វិសោធនកម្មថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (វិធានផ្ទៃក្នុង)វិធាន ៧៥(៣)នៃវិធានផ្ទៃក្នុង។

លើការសុំដាក់បង្ហាញឯកសារ ដូចដែលបានលើកឡើងនៅក្នុងសាលដីកានេះស្រាប់ និង (៣) *នៅក្នុងចំណោមបញ្ហាជាច្រើនទៀតនោះ* បានដោះស្រាយលើសំណើ D193/72 របស់ សពអ ដូចគ្នានេះដែរ ហើយពាក់ព័ន្ធនឹងការដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] និងឯកសារភ្ជាប់មកជាមួយ ដែលនាំឱ្យមានការជំទាស់តវ៉ាភាគច្រើនរបស់មេធាវីការពារក្តី។

13. នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៦ សពអ បានដាក់សំណើសុំពន្យារពេលវេលាដើម្បីធ្វើការឆ្លើយតប និងសុំការអនុញ្ញាតដាក់ចម្លើយតបតែមួយភាសាសិន ហើយការបកប្រែភាសានឹងត្រូវដាក់ជូនតាមក្រោយ[25] ដែលអង្គបុរេជំនុំជម្រះបានយល់ព្រមព្រមតាម នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦[26] ។ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ សពអ បានដាក់ចម្លើយតបជាភាសាអង់គ្លេស ហើយក្រោយមកបានដាក់សំណៅបកប្រែជាភាសាខ្មែរនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ("ចម្លើយតប")[27]។ ការ

---

[25] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេល និងសុំអនុញ្ញាតដាក់ចម្លើយតបតែមួយភាសាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឯកសារ D193/89 និង D193/90 ទាក់ទងនឹងការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D193/91/3។

[26] សេចក្តីសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេល និងសុំអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តែមួយភាសាសិន ឯកសារ D193/89 និង D193/90 ទាក់ទងនឹងការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D193/91/4។

[27] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍រួមរបស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឯកសារ D193/89 និង D193/90 ដែលទាក់ទងនឹងការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D193/91/5។

ឆ្លើយតបរបស់មេធាវីការពារក្ដីទៅនឹងសំណើរបស់ សពអ ត្រូវបានដាក់នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ("ការឆ្លើយតប")[28]។

## III. ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

### ១. សេចក្ដីសន្និដ្ឋាន

14. មេធាវីការពារក្ដី [redacted] សន្និដ្ឋានថា បណ្ដឹងឧទ្ធរណ៍នេះបានបំពេញលក្ខណវិនិច្ឆ័យដែលបានកំណត់សម្រាប់ការទទួលយកបណ្ដឹងឧទ្ធរណ៍អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[29]។ យោងតាមមេធាវីការពារក្ដី ដីកាសម្រេចដែលត្រូវបានជំទាស់រំលោភបំពានសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ សិទ្ធិទទួលបានការប្រព្រឹត្តិស្មើគ្នា និងសិទ្ធិទទួលបានភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីដែលត្រូវបានការពារអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង និងលិខិតុបករណ៍គតិយុត្តិជាធរមានផ្សេងទៀត[30]។

---

[28] ការឆ្លើយតបរបស់ [redacted] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្ដឹងឧទ្ធរណ៍រួមប្រឆាំងនឹងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឯកសារ D193/89 និង D193/90 ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D193/91/6។

[29] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៤ ដល់ កថាខណ្ឌ ២៦ *ដែលយោងលើ* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/កសចស (អបជ២៤) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធលើសំណើសុំឲ្យកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (ឯកសារ D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6 ("សាលដីកា អៀង ធីរិទ្ធ") កថាខណ្ឌ ១៣ ដល់ កថាខណ្ឌ ១៩។ សំណុំរឿង ០០២ (អបជ១១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ A190/I/20 ("សាលដីកា ខៀវ សំផន") កថាខណ្ឌ ៣៦ (អបជ៧១)។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4 ("សាលដីកា អៀង សារី") កថាខណ្ឌ ១៣។

[30] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៧ ដល់ កថាខណ្ឌ ៣៩ និងលេខយោងជើងទំព័រ ៣៨ និង ៤៦។

15. មេធាវីការពារក្ដីសន្និដ្ឋានថា ដីកាសម្រេចដែលត្រូវបានជំទាស់រំលោភបំពានសិទ្ធិរបស់ [redacted] ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់[31] ដោយហេតុថា ដីកាសម្រេចទាំងនេះ "កែប្រែទម្លាប់នៃការអនុវត្តនៃការដាក់បង្ហាញ"[32]។ ស.ច.ស.អ បានណែនាំ *"លក្ខខណ្ឌថ្មី"* មួយសម្រាប់ការដាក់បង្ហាញ[33]រយៈពេលមួយឆ្នាំក្រោយការចេញដីកាសម្រេចលើការដាក់បង្ហាញ ខែតុលា ឆ្នាំ២០១៤ របស់អតីត ស.ច.ស.អ[34]។ មេធាវីការពារក្ដីអះអាងថា "លក្ខណវិនិច្ឆ័យ[ថ្មី]នេះពិចារណាពីលក្ខខណ្ឌចំនួន ៣ នៅពេលធ្វើការសម្រេចលើសំណើសុំបង្ហាញ" ដែលរួមមាន (១) ត្រូវទទួលខុសត្រូវជាចាំបាច់លើការការពារការសម្ងាត់ និងសុចរិតភាពនៃការស៊ើបអង្កេត (២) ភាពពាក់ព័ន្ធនៃឯកសារទៅនឹងបញ្ហាក្នុងសំណុំរឿង ០០២ និង (៣) សិទ្ធិរបស់ភាគីក្នុងសំណុំរឿង ០០២[35]។ មេធាវីការពារក្ដីជំទាស់ថា លក្ខខណ្ឌថ្មីនេះ "មានលក្ខណៈខុសគ្នាខ្លាំងពីលក្ខណវិនិច្ឆ័យសម្រាប់ការដាក់បង្ហាញឯកសារដែលកំណត់ឡើងដោយអតីត ស.ច.ស.អ [...] ដែលកំណត់ថា ដីកាសម្រេចនេះត្រូវស្ថិតនៅចន្លោះ "ប្រយោជន៍ប្រឆាំងគ្នារវាងប្រយោជន៍នៃការរក្សាសុចរិតភាព និងការសម្ងាត់នៃការស៊ើបអង្កេតដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០៤ ជាមួយនឹងប្រយោជន៍នៃការបង្ហាញឱ្យទាន់ពេលវេលានូវឯកសារនានាជូនភាគីទាំងអស់ក្នុងសំណុំរឿង ០០២/០២""[36]។ លើសពីនេះទៀត យោងតាមមេធាវីការពារក្ដី លក្ខខណ្ឌថ្មីក៏ "មិនត្រូវបានកំណត់ក្នុង ឬ ផ្អែកលើ

---

[31] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៧ ប្រយោគទី១។

[32] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៧ ប្រយោគទី២។

[33] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៧ ប្រយោគទី៣ ដែលនៅក្នុងលេខយោងទំព័រ ២៩ បានយោងលើអនុស្សរណៈ D273 កថាខណ្ឌ ៣។

[34] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៨។

[35] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៨ *ដែលយោងលើ*ដីកាសម្រេចដែលត្រូវបានជំទាស់លើកទី១ កថាខណ្ឌ ៧២ ដល់ កថាខណ្ឌ ៧៣ និងកថាខណ្ឌ ៧៧ ដល់ កថាខណ្ឌ ៧៩ ។

[36] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៩ ដែលយោងលើ ដីកាសម្រេចសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១ នៃការជំនុំជម្រះក្ដីនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ឯកសារ D193/4 កថាខណ្ឌ ១១។

វិធានផ្ទៃក្នុងជាធរមានទាំងអស់ផងដែរ" ហើយ "លក្ខណវិនិច្ឆ័យនេះបានរំលោភបំពានលើវិធាន ៥៦(១) ដែលធានារក្សាការសម្ងាត់នៃការស៊ើបអង្កេត ប៉ុន្តែ ត្រូវមានករណីលើកលែងមួយចំនួនតូច ដូចមានចែងក្នុងវិធាន ៥៦(២)"[37]។ នៅក្នុងការបំពានវិធាន ៥៦ នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីសន្និដ្ឋានថា លក្ខខណ្ឌថ្មីនេះផ្ទុយនឹងវិធីសាស្ត្រដែលបានអនុវត្តដោយអង្គបុរេជំនុំជម្រះដែល "បានរកឃើញថា វិធាន ៥៦ បានផ្តល់ឆន្ទានុសិទ្ធិទូលាយដល់សហចៅក្រមស៊ើបអង្កេតក្នុងការដោះស្រាយលើបញ្ហារក្សាការសម្ងាត់ និងដាក់បង្ហាញការស៊ើបអង្កេតរបស់តុលាការ"[38]។ ជាលទ្ធផល មេធាវីការពារក្តីអះអាងថា ឯកសារទាំងនេះបានបន្តដាក់បង្ហាញ "ដោយគ្មានភាពប្រាកដប្រជាថា តើមានការអនុវត្តលក្ខណវិនិច្ឆ័យ [នៃការដាក់បង្ហាញ] ដែលត្រឹមត្រូវ និងស៊ីសង្វាក់គ្នា ឬយ៉ាងណានោះទេ" ដែលវារំលោភបំពានលើសិទ្ធិរបស់ [redacted] ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ដោយហេតុថា គាត់ "មានសិទ្ធិទទួលបានដីកាសម្រេចពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងបញ្ហានៃការដាក់បង្ហាញឯកសារដោយអនុលោមតាមវិធានផ្ទៃក្នុង"[39]។

16. មេធាវីការពារក្តីចោទប្រកាន់ទៀតថា ការបដិសេធនៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ លើសំណើសុំឱ្យសម្រេចនីត្យានុកូលភាពនៃការដាក់បង្ហាញដែលបានធ្វើឡើងក្រោមរបបនៃការដាក់បង្ហាញរបស់អតីត ស.ច.ស.អ "បំពានលើគោលការណ៍ស្មើភាពគ្នារវាងជនត្រូវចោទ"[40]។ យោងតាមមេធាវីការពារក្តី ខណៈ [redacted] "មិនមានសិទ្ធិក្នុងការដាក់សារណាលើសំណើសុំបង្ហាញឯកសាររហូតទាល់គាត់ត្រូវបានចោទប្រកាន់នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥" [redacted] និង [redacted] ដែលត្រូវបានចោទប្រកាន់មុនគាត់ "មានរយៈពេល ០៩ ខែ ដើម្បីឆ្លើយតបនឹងសំណើសុំបង្ហាញឯក

---

[37] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០។

[38] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១ ដែលយោងលើសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60 ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ("សាលដីកាលើរឿងក្តី ០០៤ (អ.ប.ជ ២៥)") ឯកសារ D284/1/4 កថាខណ្ឌ ២៣។

[39] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣២។

[40] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣។

សាររបស់ ស.ព.ជ.អ”[41]។ករណីនេះបានបណ្តាលឱ្យ “មានដីកាសម្រេចលើសំណើសុំបង្ហាញឯកសារជាច្រើនដែលមិនអាចពិចារណា ឬ ដេញដោលបានដោយមេធាវីការពារក្តីលោក [redacted]។ នេះបានធ្វើឱ្យគាត់ទទួលរងផលប៉ះពាល់អវិជ្ជមានធៀបនឹងជនត្រូវចោទផ្សេងទៀតក្នុងសំណុំរឿង ០០៤” ដែលបានបណ្តាលឱ្យមានព្យសនកម្ម “មិនអាចជួសជុលបាន” ដែល “អាចដោះស្រាយបានតាមមធ្យោបាយតែមួយគត់ គឺ អង្គបុរេជំនុំជម្រះត្រូវច្រានចោលដីកាសម្រេចរបស់ ស.ច.ស.អ ដែលមិនអនុញ្ញាតឱ្យគាត់ពិនិត្យលើដីកាសម្រេចលើសំណើសុំបង្ហាញឯកសារពាក់ព័ន្ធ”[42]។

17. ចំណុចចុងក្រោយ មេធាវីការពារក្តីសន្និដ្ឋានថា ដីកាសម្រេចដែលត្រូវបានជំទាស់បានបណ្តាលឱ្យមានការរំលោភបំពានភាពយុត្តិធម៌ផ្នែកនីតិវិធីដែលកើតមាន “ដោយសារតែការបដិសេធរបស់ ស.ច.ស.អ មិនផ្តល់សំណងដល់ភាពអយុត្តិធម៌ផ្នែកនីតិវិធីដោយសារតែ [redacted] ត្រូវបានចោទប្រកាន់នៅដំណាក់កាលក្រោយមកទៀតដែលមានរយៈពេលយូរជាងជនត្រូវចោទផ្សេងទៀតក្នុងសំណុំរឿង ០០៤”[43]។ យោងតាមមេធាវីការពារក្តី ទោះបី ទាំង ស.ច.ស.អ[44] និងអតីត ស.ច.ស.អ[45] ទទួលស្គាល់ថា ការចោទប្រកាន់ [redacted] ក្រោយគេ អាចបណ្តាលឱ្យកើតមានវិសមភាពក៏ដោយ ក៏ “ស.ច.ស.អ មិនបានដោះស្រាយវិសមភាពឡើយ ប៉ុន្តែបានចាត់ទុកថា វាធ្វើឡើង “ដោយចេតនា និងជាប្រព័ន្ធ””[46]។ មេធាវីការពារក្តីសន្និដ្ឋានថា ការបំពានលើភាពយុត្តិធម៌ផ្នែកនីតិ

---

[41] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤ ដល់ កថាខណ្ឌ ៣៥។

[42] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦។

[43] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៧។

[44] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៨ *ដែលបានយោងលើ* ដីកាសម្រេចដែលត្រូវបានជំទាស់លើកទី១ កថាខណ្ឌ ៨២។

[45] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៨ *ដែលបានយោងលើ* ដីកាសម្រេចរបស់អតីត ស.ច.ស.អ លើសំណើសុំឯកសារចំនួនប្រាំ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ (ឯកសារ D226/1) កថាខណ្ឌ ១២។

[46] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩ *ដែលបានយោងលើ* ដីកាសម្រេចដែលត្រូវបានជំទាស់លើកទី១ កថាខណ្ឌ ៨២។

វិធីនេះមិនអាចជួសជុលបាន "លុះត្រាតែដីកាសម្រេចរបស់ ស.ច.ស.អ ត្រូវបានពិនិត្យឡើងវិញដោយអង្គបុរេជំនុំជម្រះ"[47]។

18. ស.ព.ជ.អ បានសន្និដ្ឋាននៅក្នុងចម្លើយតបរបស់ខ្លួនថា បណ្ដឹងឧទ្ធរណ៍មិនអាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយហេតុថា មេធាវីការពារក្ដីបកស្រាយខុសលើទស្សនទាននៃសច្ចភាពផ្លូវច្បាប់ ការប្រព្រឹត្តិស្មើគ្នា និងភាពយុត្តិធម៌ផ្នែកនីតិវិធី[48] ហើយខកខានពុំបានបញ្ជាក់ឱ្យបានច្បាប់ថាតើដីកាសម្រេចដែលត្រូវបានជំទាស់បណ្ដាលឱ្យមានការខូចខាតមិនអាចជួសជុលបានដែលតម្រូវឱ្យ អ.ប.ជ អន្តរាគមន៍ដោយរបៀបណា[49]។ យោងតាម ស.ព.ជ.អ ការជំទាស់របស់មេធាវីការពារក្ដីថា ស.ច.ស.អ បានអនុវត្តលក្ខខណ្ឌថ្មីមួយ បានផ្អែកលើការយល់មិនត្រឹមត្រូវជាសារវន្តលើទស្សនទាននៃសច្ចភាពផ្លូវច្បាប់ និងបានផ្អែកលើការបំផ្លើសលើវិសាលភាពដែលលក្ខខណ្ឌថ្មីខុសពីលក្ខខណ្ឌចាស់[50]។ ស.ព.ជ.អ យល់ឃើញថា ទស្សនាទាននៃសច្ចភាពផ្លូវច្បាប់អនុញ្ញាតឱ្យមានការកែលម្អ និងការបង្កើតយុត្តិសាស្ត្រ ជាពិសេសពាក់ព័ន្ធនឹងបញ្ហានីតិវិធី[51] ហើយលក្ខខណ្ឌនៃការដាក់បង្ហាញទាំងពីរមានខ្លឹមសារស្រដៀងគ្នា ដោយសារលក្ខខណ្ឌទាំងពីរ "ទទួលស្គាល់ភាពចាំបាច់ដើម្បីរក្សាតុល្យភាពការទទួលខុសត្រូវរបស់ ស.ច.ស ក្នុងការការពារការសម្ងាត់ និងសុចរិតភាពនៃកិច្ចស៊ើបសួរ ជាមួយភាពចាំបាច់នៃសំណុំរឿង ០០២"[52]។ ម្យ៉ាងវិញទៀត ស.ច.ព.អ លើកឡើងថា គ្មានការបង្ហាញណាមួយថា លក្ខខណ្ឌតេស្តថ្មីនឹងពុំទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះផងដែរ[53]។ ចំពោះការព្យសនកម្មដែលបានលើកឡើង ស.ព.ជ.អ សន្និដ្ឋាន

---

[47] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩។

[48] ចម្លើយតប កថាខណ្ឌ ១៦។

[49] ចម្លើយតប កថាខណ្ឌ ១៦។

[50] ចម្លើយតប កថាខណ្ឌ ១៨។

[51] *ដូចខាងលើ ដែលបានយោងលើ ចម្លើយតប កថាខណ្ឌ ១០ ដល់ កថាខណ្ឌ ១២ និងលើយុត្តិសាស្ត្រនៃ អង្គជំនុំជម្រះតុលាកាកំពូល (អ.ជ.ត.ក)។*

[52] ចម្លើយតប កថាខណ្ឌ ១៩។

[53] ចម្លើយតប កថាខណ្ឌ ២១។

ថា មេធាវីការពារក្តីខកខានមិនបានបញ្ជាក់ឱ្យបានច្បាស់អំពីព្យសនកម្ម ដោយហេតុថា ការដាក់បង្ហាញឯកសារនៅក្នុងសំណុំរឿង ០០២ ពុំធ្វើឱ្យ [redacted] កាន់តែលំបាកក្នុងការត្រៀមរៀបចំការការពារក្តីលើរូបគាត់ ពុំបង្កើនលទ្ធភាពដែលថា គាត់នឹងត្រូវបានបញ្ជូនទៅជំនុំជម្រះ ហើយដោយសារតែ "ព្យសនកម្មដែលត្រូវបានចោទប្រកាន់ចំពោះកិត្តិយស និងភាពឯកជនរបស់ជនត្រូវចោទ ពុំជានាការអន្តរាគមន៍របស់ អ.ប.ជ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងឡើយ"[54]។ ស.ព.ជ.អ សន្និដ្ឋានបន្ថែមទៀតថា គ្មានបញ្ហាវិសមភាពណាមួយបានលេចចេញពីករណីដែលថា [redacted] ពុំមានឱកាសដូចគ្នានឹង [redacted] ហើយនឹង [redacted] ដើម្បីតវ៉ាចំពោះដីកាសម្រេចស្តីពីការដាក់បង្ហាញ ពីព្រោះភាពខុសគ្នានៃការប្រព្រឹត្តិនេះ "ពុំបានកើតមាន ជាលទ្ធផលនៃការរើសអើងតាមទំនើងចិត្ត" ផ្ទុយមកវិញ វា "បានកើតចេញពីការពិតដែលថា [redacted] និង [redacted] ត្រូវបានចោទប្រកាន់មុន [redacted] និងការពិតដែលថា វិធានផ្ទៃក្នុង [...] ប្រព្រឹត្តលើជនសង្ស័យ និងជនត្រូវចោទខុសពីគ្នា"[55]។ ចំណុចចុងក្រោយ នៅពេលកត់សម្គាល់ថា ទឡ្ហីករណ៍អំពីភាពអយុត្តិធម៌ផ្នែកនីតិវិធី "ផ្អែកលើការសន្មត ដែល" វិសមភាពបានកើតឡើង ស.ព.ជ.អ តវ៉ាថា ស.ច.ស.អ ពុំមានភារកិច្ចផ្តល់ដំណោះស្រាយលើផលវិបាកនៃភាពខុសគ្នាក្នុងការប្រព្រឹត្តិដែល "បានផ្អែកលើលក្ខណៈវិនិច្ឆ័យដែលឥតលម្អៀង"[56]។

19. មេធាវីការពារក្តីឆ្លើយតបថា ការបកស្រាយត្រឹមត្រូវលើគោលការណ៍សច្ចភាពផ្លូវច្បាប់គឺការធានាឱ្យមានភាពស៊ីសង្វាក់គ្នានៃស្ថាប័នធ្វើសេចក្តីសម្រេច[57] ហើយវិធីសាស្ត្រត្រឹមត្រូវក្នុងការអនុវត្តគោលការណ៍នេះក្នុងការបង្កើតច្បាប់នីតិវិធីមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង ដែល "ផ្ទុះបញ្ចាំងពីភារកិច្ចរបស់ចៅក្រមនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលដែលត្រូវបកស្រាយច្បាប់នីតិវិធីដើម្បី

---

[54] ចម្លើយតប កថាខណ្ឌ ២២ ដល់ កថាខណ្ឌ ២៣ *ដែលបានយោងលើ* សាលដីកា សំណុំរឿង ០០៤ (អបជ២៥) កថាខណ្ឌ ២៣។

[55] ចម្លើយតប កថាខណ្ឌ ២៤។

[56] ចម្លើយតប កថាខណ្ឌ ២៦។

[57] ការឆ្លើយតប កថាខណ្ឌ ៩។

01391457



ជាប្រយោជន៍ដល់ជនជាប់ចោទ"[58]។ មេធាវីការពារក្តីសន្និដ្ឋានបន្ថែមទៀតថា ស.ព.ជ.អ ច្របាច់បញ្ចូលសិទ្ធិទទួលបានការប្រព្រឹត្តិស្មើគ្នាដែលត្រូវបានការពារតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ[59]ជាមួយនឹងសិទ្ធិក្នុងការមិនមានការរើសអើងដែលត្រូវបានការពារដោយមាត្រា ២៦ នៃកតិកាសញ្ញាអន្តរជាតិ[60]។ មេធាវីការពារក្តីកត់សម្គាល់ថា យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស "រាល់វិសមភាពនីតិវិធីត្រូវតែផ្អែកលើ "មូលដ្ឋានសមរម្យ និងសត្យានុម័ត ដោយមិននាំទៅដល់គុណវិបត្តិពិតប្រាកដ ឬភាពអយុត្តិធម៌ផ្សេងទៀតនោះទេ""[61]។ មេធាវីការពារក្តីយល់ឃើញថា "ស.ព.ជ.អ ខកខានក្នុងការយល់ថា ភាពអយុត្តិធម៌ផ្នែកនីតិវិធីដែលបានកំណត់ [...] ហួសពីភាពខុសគ្នាក្នុងច្បាប់រវាងជនសង្ស័យ និងជនត្រូវចោទ"[62] ពីព្រោះ "ស.ព.ជ.អ មិនបានលើកឡើងពីរយៈពេលដែលលោក [redacted] ស្ថិតក្នុងស្ថានភាពជាជនសង្ស័យទេ" ដែល "មិនមែនដោយសារ "លក្ខណៈវិនិច្ឆ័យមិនលម្អៀង" "មិនដែលមានយុត្តិកម្មទេ" ហើយ "ស.ច.ស.អ មានភារកិច្ចជួសជុលភាពអយុត្តិធម៌ផ្នែកនីតិវិធីដែលកើតចេញពីការចោទប្រកាន់លោក [redacted] ដ៏យឺតយ៉ាវនេះ"[63]។ មេធាវីការពារក្តីអះអាងថា ទង្វីករណ៍នេះ "ខុសគ្នាពីទង្វីករណ៍ [...] នៅត្រង់ការប្រព្រឹត្តិដោយស្មើភាព ដែលផ្អែកលើភាពខុសគ្នាក្នុងការប្រព្រឹត្តិចំពោះលោក [redacted] និងលោកស្រី [redacted]

---

[58] ការឆ្លើយតប កថាខណ្ឌ ១១។

[59] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានអនុម័តនិងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ននិងឱ្យចូលជាសមាជិកតាមសេចក្តីសម្រេចចិត្តលេខ ២២០០A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦(កតិកាសញ្ញាអន្តរជាតិ)។

[60] ការឆ្លើយតប កថាខណ្ឌ ១៤ ដល់ កថាខណ្ឌ ២១។

[61] ការឆ្លើយតប កថាខណ្ឌ ១៩។

[62] ការឆ្លើយតប កថាខណ្ឌ ២៣។

[63] ការឆ្លើយតប កថាខណ្ឌ ២៤។

01391458



[redacted]"[64]។ ចំណុចចុងក្រោយ មេធាវីការពារក្តីសន្និដ្ឋានថា មេធាវីការពារក្តីបានកំណត់ឃើញព្យសនកម្ម ដែលមិនអាចជួសជុលបានចំពោះការរំលោភបំពាននីមួយៗ[65]។

## ២. ការពិភាក្សា

20. មេធាវីការពារក្តីសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះបានយោងលើបទប្បញ្ញត្តិក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ហើយរំលឹកថា អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចនាពេលមុនរួចហើយថា វិធាន ២១ នៃវិធានផ្ទៃក្នុង ពុំបានផ្តល់សិទ្ធិដោយស្វ័យប្រវត្តិ សម្រាប់ភាពអាចទទួលយកបាននៃប្តឹងឧទ្ធរណ៍ដើម្បីលើកឡើងអំពីបញ្ហានៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះឡើយ[66]។ ដើម្បីអាចឱ្យអង្គបុរេជំនុំជម្រះអនុវត្តយុត្តាធិការលើបណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាននេះបាន ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា នៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ អង្គបុរេជំនុំជម្រះចាំបាច់ត្រូវធ្វើការអន្តរាគមន៍ដើម្បី

---

[64] ការឆ្លើយតប កថាខណ្ឌ ២៥។

[65] ការឆ្លើយតប កថាខណ្ឌ ២៧ ដល់ កថាខណ្ឌ ៣១ *ដែលយោងលើ* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣២ កថាខណ្ឌ ៣៦ និងកថាខណ្ឌ ៣៩។

[66] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៧២ កថាខណ្ឌ ៧៣។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៩។ សូមមើលផងដែរ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥ ដែលយោងនៅក្នុងលេខយោងជើងទំព័រ ៣៤ លើសាលដីកា អ.ប.ជ D239/I/8។

[67] សំណុំរឿង ០០២ (អ.ប.ជ ៣១) ដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D130/7/3/5 កថាខណ្ឌ ៣៩។ សំណុំរឿង ០០៤ (អ.ប.ជ ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៧ កថាខណ្ឌ ២១។

*សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍រួមរបស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ [redacted] សុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76 និង D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75 និង D193/84)*

ទប់ស្កាត់ការខូចខាតដែលមិនអាចជួសជុលបានលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍[67]។

21. ចំពោះយុត្តិសាស្ត្រដែលបានសំអាងនៅក្នុងបណ្តឹងឧទ្ធរណ៍[68] អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អង្គបុរេជំនុំជម្រះបានរកឃើញថា បណ្តឹងឧទ្ធរណ៍របស់ អៀង សារី អាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយហេតុថា មេធាវីការពារក្តីបានបង្ហាញថា ទាល់តែអង្គបុរេជំនុំជម្រះបានអន្តរាគមន៍នៅក្នុងដំណាក់កាលនៅពេលបណ្តឹងឧទ្ធរណ៍បានដាក់ ទើបសិទ្ធិរបស់ អៀង សារី នៅក្នុងការទទួលបានការប្រព្រឹត្តិស្មើគ្នាទទួលរងព្យសនកម្មមិនអាចជួសជុលបាន[69]។ បណ្តឹង

---

[67] សំណុំរឿង ០០២ (អ.ប.ជ ៣១) ដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភ័ស្តុតាង និងការសំអាងទៅលើភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D130/7/3/5 កថាខណ្ឌ ៣៩។ សំណុំរឿង ០០៤ (អ.ប.ជ ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៧ កថាខណ្ឌ ២១។

[68] បណ្តឹងឧទ្ធរណ៍ លេខយោងជើងទំព័រ ៣៧។ សូមមើលខាងលើលេខយោងជើងទំព័រ ២៩។

[68] បណ្តឹងឧទ្ធរណ៍ លេខយោងជើងទំព័រ ៣៧។ សូមមើលខាងលើលេខយោងជើងទំព័រ ២៩។

[69] សាលដីកា អៀង សារី កថាខណ្ឌ ៧ ដែលយោងលើ បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយរបស់លោកអៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ឯកសារ *D390/1/2/1* ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ទំព័រ ១ និងទំព័រ ១៣។ នៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីនោះ មេធាវីការពារក្តីសន្និដ្ឋានថា ខុសពីករណី អៀង សារី ជនត្រូវចោទនៅក្នុងសំណុំរឿង ០០២ កាំង ហ្គេកអ៊ាវ ជនត្រូវចោទនៅក្នុងសំណុំរឿង ០០១ ត្រូវបាន ស.ច.ស.ច អនុញ្ញាតឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។ ដូច្នេះ លើកលែងតែអង្គបុរេជំនុំជម្រះបានអន្តរាគមន៍នៅក្នុងដំណាក់កាលពេលដែលបណ្តឹងឧទ្ធរណ៍បានដាក់ ទើបសិទ្ធិ អៀង សារី ក្នុងការទទួលបានការប្រព្រឹត្តស្មើគ្នានឹងរងព្យសនកម្មមិនអាចជួសជុលបាន។

[69] សាលដីកា អៀង សារី កថាខណ្ឌ ៧ ដែលយោងលើ បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយរបស់លោកអៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ឯកសារ

ឧទ្ធរណ៍របស់ ខៀវ សំផន ក៏ត្រូវបានរកឃើញថាមិនអាចទទួលយកបាន[70] ក្រោយពីអង្គបុរេជំនុំជម្រះសន្និដ្ឋានថា ពុំមានភ័ស្តុតាងបង្ហាញឲ្យឃើញពីការរំលោភសិទ្ធិ[71] នៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីនោះ[72]។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ពុំជាប់ពាក់ព័ន្ធនឹងរឿងក្តីកំពុងដោះស្រាយនេះឡើយ ពីព្រោះនៅក្នុងរឿងក្តីរបស់ អៀង ធីរិទ្ធ អង្គជំនុំជម្រះរកឃើញថា នៅពេលចេញដីកាដែលត្រូវបានជំទាស់ សហចៅក្រមស៊ើបអង្កេតពុំបានពិចារណាលើបញ្ហាយុត្តាធិការរបស់ចៅក្រមលើសំណើសុំនេះ[73] ដែលបង្ខំឲ្យអង្គជំនុំជម្រះសន្មតថាខ្លួនមានយុត្តាធិការលើសំណើសុំក្នុងនាមជាតុលាការសាលាដំបូង[74] ដោយសារតែពាក់ព័ន្ធនឹង "ទំនាស់ជាប្រព័ន្ធជាស្រេច"[75] នោះ។

---

*D390/1/2/1* ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ទំព័រ ១ និងទំព័រ ១៣។ នៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីនោះ មេធាវីការពារក្តីសន្និដ្ឋានថា ខុសពីករណី អៀង សារី ជនត្រូវចោទនៅក្នុងសំណុំរឿង ០០២ កាំង ហ្កេកអ៊ាវ ជនត្រូវចោទនៅក្នុងសំណុំរឿង ០០១ ត្រូវបាន ស.ច.ស.ច អនុញ្ញាតឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។ ដូច្នេះ លើកលែងតែអង្គបុរេជំនុំជម្រះបានអន្តរាគមន៍នៅក្នុងដំណាក់កាលពេលដែលបណ្តឹងឧទ្ធរណ៍បានដាក់ ទើបសិទ្ធិ អៀង សារី ក្នុងការទទួលបានការប្រព្រឹត្តស្មើគ្នានឹងរងព្យសនកម្មមិនអាចជួសជុលបាន។

70 សាលដីកា ខៀវ សំផន កថាខណ្ឌ ១៤។

70 សាលដីកា ខៀវ សំផន កថាខណ្ឌ ១៤។

71 សាលដីកា ខៀវ សំផន កថាខណ្ឌ ៥០។

71 សាលដីកា ខៀវ សំផន កថាខណ្ឌ ៥០។

72 សូមមើលជាពិសេសសាលដីកា ខៀវ សំផន កថាខណ្ឌ ៤៣៖ "អាស្រ័យលើកាលៈទេសៈជាក់លាក់នៃរឿងក្តី"។

72 សូមមើលជាពិសេសសាលដីកា ខៀវ សំផន កថាខណ្ឌ ៤៣៖ "អាស្រ័យលើកាលៈទេសៈជាក់លាក់នៃរឿងក្តី"។

73 សាលដីកា អៀង ធីរិទ្ធ កថាខណ្ឌ ១១។

73 សាលដីកា អៀង ធីរិទ្ធ កថាខណ្ឌ ១១។

74 សាលដីកា អៀង ធីរិទ្ធ កថាខណ្ឌ ១៨។

74 សាលដីកា អៀង ធីរិទ្ធ កថាខណ្ឌ ១៨។

75 សាលដីកា អៀង ធីរិទ្ធ កថាខណ្ឌ ១៧។

75 សាលដីកា អៀង ធីរិទ្ធ កថាខណ្ឌ ១៧។

22. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលថា តើនៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ ការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះនៅក្នុងដំណាក់កាលនេះចាំបាច់ធ្វើឡើងដើម្បីទប់ស្កាត់ការរំលោភបំពានដែលមិនអាចជួសជុលបានលើសិទ្ធិរបស់ [redacted] ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ សមភាព និងភាពយុត្តិធម៌ផ្នែកនីតិវិធីដែរឬទេ។

*១. សិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់*

23. អង្គបុរេជំនុំជម្រះសូមរម្លឹកថា មេធាវីការពារក្តីជំទាស់អំពីអសច្ចភាពផ្លូវច្បាប់ដោយផ្អែកលើមូលដ្ឋានថា លក្ខខណ្ឌ "ថ្មី" សម្រាប់ការដាក់បង្ហាញ ដែលបានកំណត់នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ i) ខុសគ្នាយ៉ាងខ្លាំងពីលក្ខខណ្ឌដែលបានប្រើប្រាស់នៅក្នុងសេចក្តីសម្រេចស្តីពីការដាក់បង្ហាញពីមុន ដែលអតីត ស.ច.ស.អ បានចេញ ("មូលដ្ឋានសង្គតិភាព")[76] និង ii) មិនបានផ្អែកលើវិធានជាធរមាន និងរំលោភបំពានលើវិធាន ៥៦(១) ដែលធានារក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ ប៉ុន្តែ ត្រូវមានករណីលើកលែងមួយចំនួន ដូចមានចែងក្នុងវិធាន ៥៦(២) ហេតុនេះ វាផ្ទុយពីវិធីសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ("មូលដ្ឋាននីត្យានុកូលភាព")[77]។ តទៅនេះ អង្គបុរេជំនុំជម្រះនឹងពិចារណាទៅលើមូលដ្ឋានទាំងពីរនេះ។

*i) មូលដ្ឋានសង្គតិភាព*

24. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ជាគោលការណ៍ ទាំងដីកាសម្រេចដែលត្រូវបានជំទាស់ និង ដីកាសម្រេចរបស់អតីត ស.ច.ស.អ ឆ្លើយតបទៅសំណើសុំដាក់បង្ហាញ ដោយ ជាគោលការណ៍ អនុវត្តដំណើរការរក្សាតុល្យភាពដូចគ្នារវាងការទទួលខុសត្រូវរបស់ ស.ច.ស.អ ក្នុងការធានាសុចរិត

[76] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៨ និង ២៩ និង ជើងទំព័រ ៤១-៤៤។

[76] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៨ និង ២៩ និង ជើងទំព័រ ៤១-៤៤។

[77] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០-៣១។

ភាព និងការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ[78] ព្រមទាំងការទទួលខុសត្រូវរបស់ ស.ច.ស.អ ក្នុងការសហការនៅក្នុងដំណើរការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២[79]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការពិចារណាជាក់លាក់នីមួយៗរបស់ ស.ច.ស.អ ទៅលើ "ការដាក់បង្ហាញសម្ភារដល់ភាគីក្នុងសំណុំរឿង ០០២ បានទាន់ពេលវេលា" ឬ "សិទ្ធិរបស់ភាគីក្នុងសំណុំរឿង ០០២" ឬ ទៅលើ "ភាពពាក់ព័ន្ធនៃសម្ភារក្នុងសំណុំរឿង ០០៤ ទៅនឹងបញ្ហានានានៅក្នុងសំណុំរឿង ០០២" មិនតំណាងឲ្យលក្ខណវិនិច្ឆ័យនៃការដាក់បង្ហាញថ្មីដូចដែលមេធាវីការពារក្តីបានលើកឡើងនោះទេ តែផ្ទុយទៅវិញ វាជាសេចក្តីពិចារណាជាមូលដ្ឋានដែលមានគោលបំណងធានាជាចាំបាច់ថា ក្នុងការសម្រេចទទួលយក ឬបដិសេធការដាក់បង្ហាញ ស.ច.ស.អ អនុវត្តស្របទៅនឹង "ការទទួលខុសត្រូវចម្បង" ទាំងពីររបស់គាត់ ក្នុងការសហការនៅក្នុងដំណើរការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២ ក្នុងកម្រិតមួយដែលមិនត្រូវប៉ះពាល់ដល់សុចរិតភាព និងការសម្ងាត់នៃកិច្ចស៊ើបសួរឡើយ។ ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ទឡ្ហីករណ៍ស្តីពីសង្គតិភាពរបស់មេធាវីការពារក្តីពុំមានមូលដ្ឋានទេ។

*ii) មូលដ្ឋាននីត្យានុកូលភាព*

25. តាមការលើកឡើងរបស់មេធាវីការពារក្តី លក្ខខណ្ឌថ្មីមិនត្រូវបានកំណត់ ឬផ្អែកទៅលើវិធានជាធរមានណាមួយឡើយ រំលោភបំពានទៅលើវិធាន ៥៦(១) ដែលធានារក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ ប៉ុន្តែ ត្រូវមានករណីលើកលែងមួយចំនួន ដូចមានចែងក្នុងវិធាន ៥៦(២) ហើយ ដោយរំលោភបំពានវិធាន ៥៦ វាផ្ទុយនឹងវិធីសាស្ត្រដែលអង្គបុរេជំនុំជម្រះបានអនុវត្ត ដែលមេធាវីការពារក្តីយល់

---

[78] ដីកាសម្រេចដែលរងការជំទាស់លើកទីមួយ កថាខណ្ឌ ៧៣ និង ៧៥-៧៧។ ឯកសារ D193/1 កថាខណ្ឌ ៩ និង ១១។ ឯកសារ D193/4 កថាខណ្ឌ ១៩។

[79] ដីកាសម្រេចដែលរងការជំទាស់លើកទីមួយ កថាខណ្ឌ ៧៧ និង ៧៨។ ឯកសារ D193/1 កថាខណ្ឌ ៩ និង ១១។ ឯកសារ D193/4 កថាខណ្ឌ ១៩។

ឃើញ អង្គបុរេជំនុំជម្រះ "បានបញ្ជាក់ថា វិធាន ៥៦ បានផ្ដល់ឆន្ទានុសិទ្ធិទូលាយដល់ ស.ច.ស ក្នុងការដោះស្រាយលើបញ្ហារក្សាការសម្ងាត់ *និងដាក់បង្ហាញ* ការស៊ើបអង្កេតរបស់តុលាការ"[80]។

26. តាំងពីដំបូងមក អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ចំណុចទីពីរនៃមូលដ្ឋានស្ដីពីនីត្យានុកូលភាព ដែលលើកឡើងថា "លក្ខណៈវិនិច្ឆ័យថ្មីនេះផ្ទុយនឹងវិធីសាស្ត្រដែលអនុម័តដោយអង្គបុរេជំនុំជម្រះ" ផ្អែកទៅលើការបកស្រាយមិនត្រឹមត្រូវទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះ ដែលមិនបានចែងថា "វិធាន ៥៦ គ្របដណ្ដប់លើ*ការបង្ហាញ*" ជាពិសេស ដូចដែលមេធាវីការពារក្ដីលើកឡើង និងបកស្រាយដូចតទៅ៖

> "អង្គបុរេជំនុំជម្រះសូមបញ្ជាក់ថា ក្របខណ្ឌច្បាប់ អ.វ.ត.ក ជាពិសេសវិធាន ៥៦ នៃវិធានផ្ទៃក្នុង បានផ្ដល់ឆន្ទានុសិទ្ធិទូលាយដល់សហចៅក្រមស៊ើបអង្កេតក្នុងការដោះស្រាយលើបញ្ហារក្សាការសម្ងាត់ និងផ្ដល់សិទ្ធិតិចតួចក្នុងការស៊ើបអង្កេតរបស់តុលាការ"[81]។

27. អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីវិធាន ៥៦(១) នៃវិធានផ្ទៃក្នុងផ្ដល់ឆន្ទានុសិទ្ធិទូលាយដល់សហចៅក្រមស៊ើបអង្កេតក្នុងការដោះស្រាយលើបញ្ហា*រក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ*ក៏ដោយ តែវិធាន ៥៦(២) មិនពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចលើ "ការដាក់បង្ហាញ" ឯកសារដែលកំពុងស្ថិតក្នុងកិច្ចស៊ើបសួរ សម្រាប់ "អង្គភាពតុលាការ" ផ្សេងទៀត រួមទាំងអង្គជំនុំជម្រះសាលាដំបូងទេ។

28. ទីមួយ អង្គបុរេជំនុំជម្រះផ្ដោតទៅលើចំណងជើង និងបរិបទនៃវិធាន ៥៦ នៃវិធានផ្ទៃក្នុង។ ចំណងជើងនៃវិធាន ៥៦ នៃវិធានផ្ទៃក្នុង គឺ "ការផ្ដល់ព័ត៌មានដល់សាធារណៈដោយសហចៅក្រមស៊ើបអង្កេត"[82]។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង និង កម្ពុជា ដែលជាមូលដ្ឋានរបស់វិធានផ្ទៃក្នុង ក៏ពុំមាន

---

[80] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣១ *យោងទៅ* សេចក្ដីសម្រេចលើសំណុំរឿង ០០៤ (អ.ប.ជ ២៥) កថាខណ្ឌ ២៣។

[81] សេចក្ដីសម្រេចលើសំណុំរឿង ០០៤ (អ.ប.ជ ២៥) កថាខណ្ឌ ២៣។

[82] វិធាន ៥៤ នៃវិធានផ្ទៃក្នុងមានចំណងជើងស្រដៀងគ្នាដែល ហើយក៏ឆ្លើយតបយ៉ាងច្បាស់លាស់ទៅនឹងបញ្ហានានាពាក់ព័ន្ធនឹង "ព័ត៌មានជាសាធារណៈ"។

ចែងអំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹង "ការដាក់បង្ហាញ" ទេ ហើយគ្រឹមតែចែងអំពីបញ្ហានានាពាក់ព័ន្ធនឹង "ភាពជាសាធារណៈ"[83]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះសូមរម្លឹកទៅការសម្រេចរបស់ខ្លួនថា វិធានផ្ទៃក្នុងត្រូវ "បកស្រាយនៅក្នុងបរិបទ និងស្របទៅនឹងកម្មវត្ថុ និងគោលបំណង [របស់វិធាន]"[84] និងកត់សម្គាល់ថា វិធាន ៥៦ នៃវិធានផ្ទៃក្នុង ស្ថិតនៅក្នុងផ្នែក "គ" នៃវិធានផ្ទៃក្នុង ដែលមានចំណងជើងថា "*ការស៊ើបសួរ*"។ ចំណងជើង និងបរិបទនៃវិធាន ៥៦ នៃវិធានផ្ទៃក្នុង បង្ហាញពីបទប្បញ្ញត្តិជាក់លាក់មួយពាក់ព័ន្ធនឹង *ភាពជាសាធារណៈ* នៃ*ការស៊ើបអង្កេត* តាមផ្លូវតុលាការ។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វិធាន ៥៦ នៃវិធានផ្ទៃក្នុង ស្ថិតក្នុងជំពូក "៣" នៃវិធានផ្ទៃក្នុង ដែលមានចំណងជើងថា "នីតិវិធី"។ ហេតុនេះ គោលបំណងទូទៅរបស់វាគឺ ដើម្បី *គ្រប់គ្រង "កិច្ចដំណើរការនីតិវិធី"* សម្រាប់ *ភាពជាសាធារណៈ* នៃ*ការស៊ើបអង្កេត* តាមផ្លូវតុលាការ។

29. ទីពីរ អង្គបុរេជំនុំជម្រះពិនិត្យយ៉ាងយកចិត្តទុកដាក់ចំពោះបទប្បញ្ញត្តិជាក់លាក់នៃវិធាន ៥៦(២)(ខ) នៃវិធានផ្ទៃក្នុង ដើម្បីស្វែងរកអត្ថន័យនៃពាក្យថា "អ្នកដែលមិនមែនជាភាគី" និងថាតើ វិធាននេះ

---

[83] សូមមើលមាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និង មាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[84] សំណុំរឿង ០០២ សាលដីការបស់ អ.ប.ជ គ្របដណ្តប់លើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ D404/2/4 ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២") កថាខណ្ឌ ៦០៖ "អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ក្នុងពេលអនុវត្តវិធានរបស់ខ្លួន តុលាការព្រហ្មទណ្ឌអន្តរជាតិ បានស្វែងរកគោលការណ៍ណែនាំពីបណ្តាគោលការណ៍ដែលមានចែងក្នុងអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា។ តុលាការព្រហ្មទណ្ឌអន្តរជាតិយល់ឃើញថា "បទប្បញ្ញត្តិនេះគួរ*ត្រូវបានបកស្រាយ ក្នុងបរិបទ ព្រមទាំងស្របទៅតាមគោលដៅ*" ហើយថា គោលការណ៍នេះ "អនុវត្តចំពោះវិធាន"។ តុលាការនេះបានពន្យល់ទៀតថា "*បរិបទនៃបទប្បញ្ញត្តិច្បាប់ដែលបានលើកឡើង គឺត្រូវបានកំណត់ដោយផ្នែកជាក់លាក់មួយនៅក្នុងច្បាប់ ដែលត្រូវបកស្រាយទាំងស្រុង ដោយបកស្រាយរួមជាមួយនឹងផ្នែកនៃបញ្ញត្តិច្បាប់ទាំងមូលតែម្តង*" ហើយថា "*គោលដៅរបស់វា អាចប្រមូលយកពីជំពូកមួយនៃច្បាប់ ដែលក្នុងជំពូកនេះមានរួមបញ្ចូលនូវផ្នែកជាក់លាក់មួយនេះ ហើយគោលបំណងរបស់វា អាចប្រមូលយកពីគោលដៅដ៏ទូលំទូលាយនៃច្បាប់ ដែលចំណុចទាំងនេះ អាចប្រមូលយកពីបុព្វកថា និងច្បាប់ទូទៅ*"។ អង្គបុរេជំនុំជម្រះនឹងពិចារណាលើគោលការណ៍ណែនាំ ទាក់ទិនដល់ការអនុវត្តវិធានឱ្យបានសមស្រប"។

*សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍រួមរបស់* [redacted] *ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់* [redacted] *សុំឱ្យពិចារណាឡើងវិញលើការដាក់បង្ហាញឯកសារ (D193/76 និង D193/77) និងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ (D193/72) និងប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (D193/70, D193/72, D193/75 និង D193/84)*

មានលើកឡើងពីពាក្យថា "អង្គភាពតុលាការ" ឬ កាន់តែភាពជាក់លាក់ទៀត គឺ "អង្គជំនុំជម្រះសាលាដំបូង"ដែរទេ។ ដំបូង អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការប្រើពាក្យ "អ្នកដែលមិនមែនជាភាគី" ជំនួស[85] ពាក្យ "សារព័ត៌មាន" បង្ហាញថា "អ្នកដែលមិនមែនជាភាគី" ត្រូវមានឋានៈ និងផលប្រយោជន៍ ស្មើនឹងអ្នក "សារព័ត៌មាន" ដែលផលប្រយោជន៍ជាចម្បងរបស់ខ្លួនក្នុងការ "ជូនដំណឹងដល់សាធារណជន" ហើយឋានៈរបស់ពួកគេគឺជាបុគ្គលដែល "មិនពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ"ទេ។ ហេតុនេះ ពាក្យថា "អ្នកដែលមិនមែនជាភាគី" ពុំអាចត្រូវបានបកស្រាយថារួមទាំង "អង្គភាពតុលាការ" ដែល បើតាមនិយមន័យ[86] ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ ហើយបេសកកម្មសំខាន់របស់អង្គភាពតុលាការនេះ ពុំមែនជូនដំណឹងដល់សាធារណជនទេ តែផ្ទុយទៅវិញត្រូវស្វែងរកការពិតនៅក្នុងសំណុំរឿងនានានៅចំពោះមុខ អ.វ.ត.ក[87]។ ទោះបីភាពជាសាធារណៈគឺជាលក្ខខណ្ឌចម្បងនៃសវនាការ *ជំនុំជម្រះក្តី* ក៏ដោយ[88] តែចំណុចនេះមិនផ្តល់ផលប្រយោជន៍ដល់អង្គជំនុំជម្រះស្រដៀងទៅនឹងផលប្រយោជន៍របស់សារព័ត៌មានទេ។ ជាងនេះទៀត អ្នកបកស្រាយដែលមិនលម្អៀងនឹងយល់ថា ពាក្យថា "អ្នកដែលមិនមែនជាភាគី" នៅក្នុងបរិបទនៃពាក្យពេចន៍ជារួមនៃវិធាន ៥៦(២)(ខ) នៃវិធានផ្ទៃក្នុង ដែលព្រមានដល់ "សារព័ត៌មាន និង អ្នកដទៃទៀតដែលមិនមែនជាភាគី" ថា ការមិនគោរពទៅតាមលក្ខខណ្ឌនានាដែលបានតម្រូវ អាចនឹងទទួលរងទណ្ឌកម្មតាមវិធាន ៣៥ និង ៣៨ នៃវិធានផ្ទៃក្នុង ដែលកម្មវត្ថុនៃវិធានទាំងនេះមិនមែនអង្គភាពតុលាការនៃ អ.វ.ត.ក ទេ។ ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ពាក្យថា "អ្នកដែលមិនមែនជាភាគី" តាមវិធាន ៥៦(២)(ខ) នៃវិធានផ្ទៃក្នុង មិនសំដៅដល់ "អ.វ.ត.ក" ជាទូទៅ ឬ ជាក់លាក់ "អង្គជំនុំជម្រះសាលាដំបូង" នោះទេ។

---

85 *កត់សម្គាល់* ការប្រើពាក្យ "ឬ" នៅក្នុងវិធាន ៥៦(២)(ខ) នៃវិធានផ្ទៃក្នុង។

86 ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២ថ្មី វិធាន ១៧(១) នៃវិធានផ្ទៃក្នុង។

87 ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (*សូមមើល* ជំពូក ២)។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង) មាត្រា ២(១)។

88 កិច្ចព្រមព្រៀង មាត្រា ១៣(១)។

30. ទីបី អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធាន ៥៦(២)(ក) និង (ខ) នៃវិធានផ្ទៃក្នុង ដែលមានចែងអំពី "ការផ្តល់ព័ត៌មាន" ឬអំពី "ការអនុញ្ញាតឱ្យចូលពិនិត្យ" គួរតែបកស្រាយដើម្បី*បម្រើកម្មវត្ថុ និងគោលបំណងរួម* នៃវិធាន ៥៦ នៃវិធានផ្ទៃក្នុង ដែលគ្រប់គ្រងកិច្ចដំណើរការនីតិវិធីសម្រាប់ "*ភាពជាសាធារណៈ*" នៃការស៊ើបអង្កេតតាមផ្លូវតុលាការ។ អនុវិធាន ៥៦(២)(ខ) មិនអាចយកមកបកស្រាយថាជាការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីដែលបម្រើកម្មវត្ថុ និង គោលបំណងខុសពីកម្មវត្ថុ និងគោលបំណងនៃអនុវិធាន ៥៦(២)(ក) នោះទេ[89]។ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើរបស់ ស.ព.អ សុំដាក់បង្ហាញ ពុំមានគោលបំណង*បញ្ចេញជាសាធារណៈ* នូវការស៊ើបអង្កេតតាមផ្លូវតុលាការទេ តែផ្ទុយទៅវិញ ផ្អែកលើភាពចាំបាច់ក្នុងការបង្ហាញភ័ស្តុតាង នៅចំពោះមុខអង្គភាពតុលាការមួយទៀតនៅ អ.វ.ត.ក ក្នុងគោលបំណង "ស្វែងរកការពិត" ហេតុនេះ*បម្រើគោលបំណងក្រៅពីភាពជាសាធារណៈ* ដូចមានចែងក្នុងវិធាន ៥៦។

31. ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា កិច្ចដំណើរការនីតិវិធីស្តីពីការដាក់បង្ហាញ ដូចដែលកិច្ចដំណើរការនីតិវិធីនានាដែល ស.ព.អ បានស្នើសុំ ផ្អែកតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ពុំត្រូវបានកំណត់ដោយវិធាន ៥៦(២)(ខ) នៃវិធានផ្ទៃក្នុងទេ។

32. អង្គបុរេជំនុំជម្រះយល់ស្របជាមួយ ស.ច.ស.អ ដែលថា មានភាពខ្វះចន្លោះនៅក្នុងច្បាប់ជាធរមាន ទាក់ទិននឹងនីតិវិធីដែលយកមកអនុវត្តនៅពេលមានសំណើសុំដាក់បង្ហាញនៅចំពោះមុខ ក.ស.ច.ស[90]។ អនុលោមតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង មាត្រា ២៣ថ្មីនៃច្បាប់ អ.វ.ត.ក និង វិធាន ២ នៃវិធានផ្ទៃក្នុង នៅពេលច្បាប់ជាធរមានមិនបានលើកឡើងពីបញ្ហាជាក់លាក់ណាមួយ គេអាចស្វែងរកការណែនាំនៅក្នុងវិធាននីតិវិធីដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ដោយយក

---

[89] *សូមមើល*ផងដែរ អនុវិធាន ៥៦(៣) ដែលចង្អុលរួមគ្នាដល់ "*បញ្ហាដែលមានយោងនៅក្នុងអនុវិធាន ២* ខាងលើ" ជាជាងយោងដល់ វិធាន ៥៦(២)(ក) ដាច់ស្រឡះពី វិធាន ៥៦(២)(ខ) នៃវិធានផ្ទៃក្នុង។

[90] *សូមមើល* ដីកាសម្រេចដែលរងការជំទាស់លើកទីមួយ កថាខណ្ឌ ៦៣៖ "វិធានផ្ទៃក្នុងមិនបានចែងឱ្យច្បាស់អំពីការដាក់បង្ហាញឯកសារពីកិច្ចស៊ើបសួរជូនអង្គជំនុំជម្រះសាលាដំបូង ដែលនេះក៏ជាសេចក្តីសន្និដ្ឋានមួយរបស់អតីតសហចៅក្រមស៊ើបអង្កេត ដែលខ្ញុំជំនួសតំណែង។ ការអនុវត្តនេះក៏មិនមានចែងនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែរ"។

ចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាសារវ័ន្តដែលមានចែងនៅក្នុងវិធាន ២១ និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ ស.ច.ស.អ បានស្នើសុំការណែនាំនៅក្នុងវិធាននានាដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ[91] និងនៅក្នុងយុត្តិសាស្ត្ររបស់បារាំង[92] និងបានសន្និដ្ឋាន ១) ថា បើតាមយុត្តិសាស្ត្រស្តីពីសិទ្ធិមនុស្សអន្តរជាតិ "សិទ្ធិទទួលបានការសន្មតថាគ្មានទោស មិនហាមឃាត់មិនឱ្យដាក់បង្ហាញព័ត៌មានទេ"[93] ២) ថា "ជាការត្រឹមត្រូវដែលនិយាយថា [...] ការដាក់បង្ហាញឯកសាររវាងសំណុំរឿងព្រហ្មទណ្ឌដាច់ដោយឡែកពីគ្នា ពាក់ព័ន្ធនឹងជនជាប់ចោទផ្សេងគ្នា ត្រូវបានអនុញ្ញាត" ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY)[94] និង ៣) ថា បើតាមតុលាការកំពូលបារាំង "(i) មិនមានបទប្បញ្ញត្តិច្បាប់ដែលហាមឃាត់មិនឱ្យប្រើប្រាស់ភស្តុតាងទទួលបានពីកិច្ចស៊ើបសួរនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌផ្សេងទៀត ដែលអាចចូលរួមចំណែកបញ្ជាក់ការពិតឡើយ ក្នុងលក្ខខណ្ឌថា ការដាក់បង្ហាញឯកសារនេះមានលក្ខណៈតទល់ចំពោះមុខ និងឯកសារទាំងនេះត្រូវបានពិភាក្សាដោយភាគីនានា ហើយ (ii) ការសម្ងាត់កិច្ចស៊ើបសួរមិនរារាំងមិនឱ្យដាក់បង្ហាញ ឬប្រើប្រាស់ភស្តុតាងទទួលបានពីកិច្ចស៊ើបសួរនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌមួយផ្សេងទៀត ដែលអាចចូលរួមចំណែកបញ្ជាក់ការពិតនៅក្នុងកិច្ចដំណើរការនីតិវិធីនោះឡើយ"[95] "យុត្តិសាស្ត្រនេះមិនតម្រូវថា ការដាក់បង្ហាញឯកសារត្រូវអនុញ្ញាតតែក្នុងករណីពិសេសឡើយ"[96] ហើយ "ការដាក់របាំងទាបសម្រាប់ការដាក់បង្ហាញឯកសារ គឺថា ភស្តុ

---

[91] ដីកាសម្រេចដែលរងការជំទាស់លើកទីមួយ កថាខណ្ឌ ៦៣ និងជើងទំព័រ ៨៥ *យោងទៅ* យុត្តិសាស្ត្រពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) និងតុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR)។ *កត់សម្គាល់*ថា តុលាការ ECtHR ពិនិត្យភាគច្រើនទៅលើយុត្តាធិការតាមប្រព័ន្ធស៊ីវិលឡូ។

[92] ដីកាសម្រេចដែលរងការជំទាស់លើកទីមួយ កថាខណ្ឌ ៦៨-៧១។

[93] ដីកាសម្រេចដែលរងការជំទាស់លើកទីមួយ កថាខណ្ឌ ៥៧។

[94] ដីកាសម្រេចដែលរងការជំទាស់លើកទីមួយ កថាខណ្ឌ ៦៣។

[95] ដីកាសម្រេចដែលរងការជំទាស់លើកទីមួយ កថាខណ្ឌ ៦៩។

[96] ដីកាសម្រេចដែលរងការជំទាស់លើកទីមួយ កថាខណ្ឌ ៧០។

តាងនោះគ្រាន់តែចាំបាច់ត្រូវចូលរួមចំណែក "បញ្ជាក់ការពិត" ជាគោលការណ៍មួយដែលគាំទ្រផង ដែរដោយច្បាប់នៅ អ.វ.ត.ក នៅក្នុងវិធាន ៨៥(១), ៨៧(៤) និង ៩១(៣) នៃវិធានផ្ទៃក្នុង"[97]។

33. អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់ ស.ច.ស.អ ស្របទៅនឹង i) លក្ខខណ្ឌតម្រូវជាសារវ័ន្តដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីឱ្យមានតុល្យភាពរវាងផលប្រយោជន៍ និងសិទ្ធិនានារបស់ភាគីពាក់ព័ន្ធក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក និង ii) ការបកស្រាយវិធាន "ក្នុងបរិបទ ព្រមទាំងស្របទៅតាមគោលដៅ និងគោលបំណង" របស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់ អ.វ.ត.ក និង កិច្ចព្រមព្រៀង[98]។ នៅក្នុងបរិបទច្បាប់នេះ ស.ច.ស.អ លើកឡើងយ៉ាងត្រឹមត្រូវថា ដើម្បីឱ្យមានភាពស្របច្បាប់ កិច្ចដំណើរការនីតិវិធីនៃការដាក់បង្ហាញត្រូវតែធ្វើឡើងទៅតាមលក្ខណៈមួយដែលធានាថា i) មុនពេលចេញដីកាសម្រេចដាក់បង្ហាញ ភាគីក្នុងកិច្ចស៊ើបសួរទទួលបានអនុញ្ញាតឱ្យមានលទ្ធភាពក្នុងការពិភាក្សាតទល់ទៅលើសំណើស្តីពីការដាក់បង្ហាញ[99] ហើយថា ii) ក.ស.ព អាចបន្តអាណត្តិការងាររបស់ខ្លួនក្នុងការធ្វើការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២[100] ហើយ អ.ជ.ស.ដ ទទួលបានជំនួយក្នុងការបំពេញអាណត្តិការងាររបស់ខ្លួនក្នុងការស្វែងរកការពិតនៅក្នុងសំណុំរឿង ០០២ ក្នុងអំឡុងពេលវេលាសមស្រប[101]។

34. ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា i) ដីកាសម្រេចដែលត្រូវបានជំទាស់មិនបានរំលោភបំពានលើវិធាន ៥៦ នៃវិធានផ្ទៃក្នុងទេ ហើយ ii) ផ្អែកលើវិធានជាធរមាន ត្រូវបានបកស្រាយក្នុងបរិបទ

---

[97] *ដូចយោងខាងលើ*។

[98] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ កថាខណ្ឌ ៦០។

[99] អនុលោមតាមវិធាន ៥៦(១) នៃវិធានផ្ទៃក្នុង ក.ស.ច.ស មានការទទួលខុសត្រូវក្នុងការធានារក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ "*ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី*"។

[100] កិច្ចព្រមព្រៀង មាត្រា ៦(១)។ *សូមមើល* វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង។

[101] មាត្រា ២ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ មាត្រា ២៧(៣) នៃកិច្ចព្រមព្រៀង។ វិធាន ១៧(១), ២១(៤), ៨០(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។

ហើយស្របទៅនឹងកម្មវត្ថុ និងគោលបំណង ដូចមានចែងក្នុងច្បាប់ អ.វ.ត.ក និង កិច្ចព្រមព្រៀង និងទៅតាមគោលការណ៍ជាសារវ័ន្តនៃនីតិវិធីដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង។

*២. សិទ្ធិទទួលបានសមភាព*

35. មេធាវីការពារក្តីយល់ឃើញថា ដីកាសម្រេចដែលត្រូវបានជំទាស់រំលោភបំពានទៅលើសិទ្ធិរបស់ [redacted] ក្នុងការទទួលបានការប្រព្រឹត្តិស្មើគ្នា ព្រោះថា គាត់ត្រូវបានបដិសេធមិនឲ្យជំទាស់ទៅនឹងដីកាសម្រេចស្តីពីការដាក់បង្ហាញរបស់អតីត ស.ច.ស.អ ចំណែក [redacted] និង [redacted] ដែលបានទទួលការចោទប្រកាន់មុនគាត់ អាចឆ្លើយតបទៅនឹងសំណើសុំស្តីពីការដាក់បង្ហាញរបស់ ស.ព.អ ដែលដីកាទាំងនោះបានដោះស្រាយ។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាសម្រេចដែលត្រូវបានជំទាស់លើកឡើងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> "នេះ [...] *សិទ្ធិខុសគ្នាក្នុងការចូលរួម* ដែលជនស្ថិតក្រោមការស៊ើបសួរអាចទទួលបាននៅក្នុងដំណាក់កាលផ្សេងៗគ្នានៃកិច្ចដំណើរការនីតិវិធី *ហេតុនេះមិនដូចគ្នាជាមួយនឹងករណីដែលជនណាម្នាក់មិនបានទទួលសិទ្ធិដែលខ្លួនមានសិទ្ធិទទួលឡើយ*។ និយាយម្យ៉ាងទៀត *ភាពមិនស្មើគ្នានេះគឺ [...] មិនផ្អែកលើការអនុវត្តច្បាប់ដោយភាន់ច្រឡំឡើយ*។ មេធាវីការពារក្តី មិនបានបញ្ជាក់ថាតើ សិទ្ធិរបស់ [redacted] អាចត្រូវប៉ះពាល់ជាពិសេសយ៉ាងណា ដែលអ្នករៀបចំវិធានផ្ទៃក្នុងមិនបានគិតដល់នោះទេ"[102]។

36. អង្គបុរេជំនុំជម្រះសង្កេតឃើញថែមទៀតថា ដូចដែលមេធាវីការពារក្តីបានរម្លឹកផងដែរថា បើតាមបទដ្ឋានដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ វិសមភាពនៅក្នុងការប្រព្រឹត្តិអាចត្រូវបានអនុញ្ញាត ប្រសិនបើ "ផ្អែកលើមូលដ្ឋានសមរម្យ និងសត្យានុម័ត ដោយមិននាំទៅដល់គុណវិបត្តិពិតប្រាកដ ឬភាពអយុត្តិធម៌ផ្សេងទៀតនោះទេ"[103]។

---

[102] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨២។

[103] ការឆ្លើយតប កថាខណ្ឌ ១៩ *យោងទៅ* កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ។

37. ដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅពេលចេញដីកាសម្រេច D193/15 និង D193/24 អតីត ស.ច.ស.អ បានចាត់ទុក [redacted] ជា "ជនសង្ស័យ"[104] ហើយ [redacted] និង [redacted] ជា "ជនត្រូវចោទ"[105]។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ពុំមានការជំទាស់ទេដែលថា ស.ច.ស.អ បានប្រព្រឹត្តចំពោះ "ជនសង្ស័យ" ទាំងអស់នៅក្នុងសំណុំរឿង ០០៤ ដូចៗគ្នា ដោយសារពួកគេពុំបានទទួលសិទ្ធិចូលរួមក្នុងកិច្ចស៊ើបសួរទេ រហូតទាល់តែពួកគេក្លាយជា "ជនត្រូវចោទ"។ [redacted] ពុំទទួលបានករណីលើកលែងខុសពីវិធានដែល ស.ច.ស.អ បានកំណត់នោះទេ ពាក់ព័ន្ធនឹងភាពខុសគ្នានៃសិទ្ធិចូលរួមក្នុងកិច្ចស៊ើបសួររវាង "ជនសង្ស័យ" និង "ជនត្រូវចោទ"។ [redacted] និង [redacted] បានទទួលសិទ្ធិចូលរួមក្នុងកិច្ចស៊ើបសួរ ដោយសារ នៅពេលអតីត ស.ច.ស.អ ចេញដីកាសម្រេចដែលលើកយកពិភាក្សានៅពេលនេះ អ្នកទាំងពីរទទួលបានឋានៈខុសពីឋានៈរបស់ [redacted]។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ភាពខុសគ្នាជាក់លាក់ក្នុងការប្រព្រឹត្តិគឺផ្អែកលើមូលដ្ឋានសមរម្យ និងសត្យានុម័ត និងនៅក្នុងកាលៈទេសៈណាក៏ដោយ មិនបាននាំមកនូវគុណវិបត្តិ ឬ ភាពអយុត្តិធម៌មក [redacted] បើធៀបនឹង "ជនសង្ស័យ" ផ្សេងទៀតទេ។

38. ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា នៅក្នុងកាលៈទេសៈជាក់ស្តែងនៃរឿងក្តីនេះ មេធាវីការពារក្តីមិនបានបង្ហាញថា ការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះជាការចាំបាច់ក្នុងការការពារសិទ្ធិរបស់ [redacted] ក្នុងការទទួលបានសមភាពនោះទេ។

*៣. សិទ្ធិទទួលបានយុត្តិធម៌ផ្នែកនីតិវិធី*

39. មេធាវីការពារក្តីអះអាងថា ភាពអយុត្តិធម៌ផ្នែកនីតិវិធីកើតឡើងដោយសារ [redacted] ត្រូវបានចោទប្រកាន់នៅពេលក្រោយមកខ្លាំងបើធៀបនឹងពេលចោទប្រកាន់ជនត្រូវចោទផ្សេងទៀតក្នុងសំណុំរឿង ០០៤[106] ដែលហួសពីភាពខុសគ្នាជាខ្លាំងតាមផ្លូវច្បាប់រវាងជនសង្ស័យ និងជនត្រូវ

[104] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤។

[105] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៥។

[106] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៧។

ចោទ[107]។ បើតាមមេធាវីការពារក្តី ការដែល [redacted] មិនត្រូវបានចោទប្រកាន់អស់រយៈពេលជាយូរ ពុំមែនដោយសារតែលក្ខណវិនិច្ឆ័យសត្យានុម័តនោះទេ ហើយការសម្រេចចោទប្រកាន់ [redacted] នៅក្នុងដំណាក់កាលចុងក្រោយនៅក្នុងកិច្ចស៊ើបសួរ ពុំសមហេតុផលទេ។ មេធាវីការពារក្តីយល់ឃើញថា ការចោទប្រកាន់យឺតបែបនេះបណ្តាលឱ្យមានវិសមភាពក្នុងការប្រព្រឹត្តិរវាងជនសង្ស័យ និងជនត្រូវចោទ ហើយការដែល ស.ច.ស.អ មិនបានដោះស្រាយចំពោះវិសមភាពនេះ ជាការរំលោភបំពានទៅលើភាពយុត្តិធម៌ផ្នែកនីតិវិធី[108]។

40. ទាក់ទិននឹងភាពសមហេតុផលនៃពេលវេលាដែល ស.ច.ស.អ បានចំណាយ ក្នុងការចោទប្រកាន់ [redacted] អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង មិនបានកំណត់លក្ខខណ្ឌពេលវេលាដែលត្រូវចោទប្រកាន់ជនសង្ស័យដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ។ អាស្រ័យទៅលើដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី បញ្ហានេះស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបអង្កេត។ ជាពិសេសទៅទៀត អនុលោមតាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតមានអំណាចឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់បុគ្គលណាម្នាក់នៅពេលមានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់ដែលបង្ហាញថា បុគ្គលនោះអាចមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការប្រព្រឹត្តិអំពើឧក្រិដ្ឋដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ក្រៅតែពីការអះអាងថា ស.ច.ស.អ បានចំណាយពេលច្រើនក្នុងការចោទប្រកាន់ [redacted] និងការអះអាងថា ទង្វើនោះ "ពុំមែនជាលក្ខណវិនិច្ឆ័យសត្យានុម័ត" ឬ "ពុំសមហេតុផល" មេធាវីការពារក្តីពុំបានផ្តល់ភស្តុតាងអ្វីដែលបង្ហាញពីការបំពានឆន្ទានុសិទ្ធិដោយ ស.ច.ស.អ ចំពោះការចោទប្រកាន់យឺតយ៉ាវនោះទេ។

---

[107] ការឆ្លើយតប កថាខណ្ឌ ២៣។

[108] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩។

41. ហេតុនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា នៅក្នុងកាលៈទេសៈជាក់ស្តែងនៃរឿងក្តីនេះ មេធាវីការពារក្តី ពុំបានបង្ហាញពីការប៉ះពាល់ដល់សិទ្ធិរបស់ [redacted] ក្នុងការទទួលបានភាពយុត្តិធម៌ផ្នែកនីតិវិធីនោះទេ។

## ៣. សេចក្តីសន្និដ្ឋាន

42. អង្គបុរេជំនុំជម្រះសន្និដ្ឋានថា អង្គហេតុ និងកាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍ ពុំតម្រូវឱ្យអង្គជំនុំជម្រះត្រូវធ្វើការបកស្រាយវិធានតាមន័យទូលាយ ឬត្រូវទទួលយកបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ ទេ។

## សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

មិនទទួលយកបណ្តឹងឧទ្ធរណ៍នេះទេ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។

**រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier Beauvallet** **នីយ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**